# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៤០ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការប្រគល់សិទ្ធិកាន់កាប់ទីតាំងដីដែលមាន ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ សរ.០០០៦៦៨ ចុះថ្ងៃទី ២៥-១-៩៦

*****

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកត/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ ០២អនក្រ.បក ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០០ស្តីពីការលុបចោលដីកាលេខ១៤១សសរ ចុះថ្ងៃទី២៧ ខែ តុលា ឆ្នាំ ១៩៩៥ របស់សាលាខេត្តសៀមរាប

## សំរេច

មាត្រា១ : ប្រគល់សិទ្ធិកាន់កាប់ទីតាំងដីស្ថិតនៅប៉ែកខាងលិចផ្លូវទៅអង្គរវត្តទល់មុខសាលាតុរកោសល្យវិក្រឹត្យការ ខេត្តសៀមរាប ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខសរ.០០០៦៦៨ ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ ១៩៩៦ ជូនលោក គាន គាយ្សូ វិញ ។

**មាត្រា២** : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ អាជ្ញាធរអប្សរា អភិបាលខេត្តសៀមរាប គ្រប់ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ និងលោក **តាន សាឃូ** ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- ដូចមាត្រា៣
- ឯកសារ- កាលប្បវត្តិ